# សិលាចារឹកលើចម្លាក់ឧមាមហេស្វរគង់លើគោ K.១៤០៧

ប្រាសាទបាសែត មានឈ្មោះបុរាណថា «ស្រីជ័យក្សេត្រ» (ឝ្រីជយក្សេត្រ) ស្ថិតនៅក្នុងភូមិបាសែត ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង កសាងឡើងនៅក្នុងរាជ្យព្រះបាទសូរ្យវម៌្មទេវទី១ (សូរ្យវរ្ម័នទី១៖ ១០០២-១០៥០ គ.ស.)។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានចាប់ផ្ដើមជួសជុលប្រាសាទនេះពីចុងឆ្នាំ២០១៥ និងបញ្ចប់គម្រោងនៅក្នុងឆ្នាំ២០១៨។ នៅកំឡុងពេលជួសជុលនោះ គេបានរកឃើញបដិមាមួយចំនួនជាបន្តបន្ទាប់ ដែលក្នុងចំណោមបដិមាទាំងនោះ ក្រុមការងារបានរកឃើញចម្លាក់ឧមាមហេស្វរគង់លើគោនន្ទី។ បច្ចុប្បន្នចម្លាក់នេះដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរខេត្តបាត់ដំបង ដោយចុះលេខ បប.ក.០៨៤៤ ក្នុងបញ្ជីសារពើភណ្ឌរបស់សារមន្ទីរខេត្តបាត់ដំបង និងចុះលេខ K.១៤០៧ ក្នុងបញ្ជីសារពើភណ្ឌសិលាចារឹកខ្មែរ។

លោក ឡេង ស៊ីរ៉េង[១] បានព័ណ៌នាបដិមានេះថាជាប្រភេទចម្លាក់ក្រឡោតខ្ពស់ពោល គេអាចមើលឃើញរូបរាងបដិមាបានតែផ្នែកខាងមុខប៉ុណ្ណោះ ព្រោះនៅផ្នែកខាងក្រោយនៃបដិមាមានផ្ទៃថ្មធ្វើជាជញ្ជាំងបិទបាំង។ ក្រៅពីនេះ ចម្លាក់មានលក្ខណៈផុសខ្លាំងចេញពីផ្ទៃជញ្ជាំង ដែលលក្ខណៈបែបនេះ ខុសពីប្រភេទចម្លាក់ក្រឡោតទាបដែលមានការផុសចេញពីផ្ទៃជញ្ជាំងតែបន្តិចបន្តួចតែប៉ុណ្ណោះ និងខុសពីប្រភេទចម្លាក់ទោលដែលមិនមានផ្ទៃថ្មនៅខាងក្រោយ ដែលអាចឱ្យយើងមើលឃើញដងខ្លួនទាំងស្រុងនៃបដិមា។ រូបបដិមានេះមានការបាក់បែកខូចខាតផ្នែកសំខាន់ៗមួយចំនួន តែបើទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែអាចមើលស្គាល់បានដែរថាបដិមានេះជាទេវរូបភេទប្រុសគង់បញ្ឈរព្រះជានុ(ជង្គង់)ស្ដាំ ព្រះហស្ដដាក់លើព្រះឱរូទាំងសងខាង។ នៅខាងឆ្វេងទេវរូបប្រុស ជារូបទេវរូបភេទស្រីគង់បត់ព្រះបាទ ដែលព្រះហស្ដស្ដាំចាប់ព្រះហស្ដឆ្វេងទេវរូបប្រុស។ អ្វីដែលគួរឱ្យកត់សម្គាល់មួយទៀតគឺ ទេវរូបទាំងពីរអង្គគង់លើសត្វជាពាហនៈ

[១] លោកជាបេក្ខជនបណ្ឌិតប្រវត្តិសិល្បៈ នៃសាកលវិទ្យាល័យសិល្បករ ប្រទេសថៃ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ដែលមានលក្ខណៈជាសត្វគោ ដោយយើងអាចសង្កេតបានតាមរយៈរូបរាង ជើង និងជាពិសេសនៅផ្នែកបួរ ដែលនេះជាលក្ខណៈពិសេសរបស់សត្វគោ។ តាមរយៈលក្ខណៈបដិមាខាងលើនេះធ្វើឱ្យយើងអាចសន្និដ្ឋានបានថា បដិមានេះជារូប «ឧមាមហេសូរគង់លើគោនន្ទី» ដោយចម្លាក់ក្នុងទម្រង់បែបនេះ យើងប្រទះឃើញយ៉ាងច្រើននៅក្នុងសិល្បៈខ្មែរ ដូចជាចម្លាក់ព្រះឧមាមហេសូរនៅលើផ្តែរប្រាសាទព្រៃថ្នល់ខាងជើង ផ្តែរប្រាសាទមឿងតាំ និងតាមហោជាងប្រាសាទខ្មែរជាច្រើនផ្សេងទៀត[២]។

ចំណុចសំខាន់ដែលយើងនឹងលើកមកបង្ហាញនៅទីនេះ គឺអត្ថបទចារឹកដែលចារនៅលើបដិមាមួយនេះ។ សិលាចារឹកនេះចារពីរភាសា គឺភាសាខ្មែរសម័យអង្គរ និងភាសាសំស្ក្រឹត។ បើពិនិត្យតាមទម្រង់អក្សរតែម្យ៉ាង យើងអាចសន្និដ្ឋានបានថាស្ថិតនៅក្នុងអំឡុងសតវត្សទី១០ ប៉ុន្តែតាមទម្រង់សិល្បៈ នរនាម និងតួលេខកាលបរិច្ឆេទដែលដាច់បាត់តួខាងដើម យើងអាចសន្និដ្ឋានថាចារឡើងក្នុងអំឡុងដើមស.វ.ទី១១ ក្នុងរាជ្យរបស់ព្រះបាទសូរ្យវម៌្មទី១។ តាមទម្រង់សិល្បៈរបស់ចម្លាក់នេះ គេអាចដឹងថាស្ថិតនៅអន្តរកាលរវាងរចនាបថបន្ទាយស្រីនិងរចនាបថឃ្លាំង គឺរវាងពាក់កណ្តាលទីពីរសតវត្សទី១០ និងដើមសតវត្សទី១១[៣]។

យើងពុំអាចទទួលបានព័ត៌មានលម្អិតទាំងស្រុងនៃសិលាចារឹកនេះឡើយ ដ្បិតផ្នែកសំខាន់ៗ បានបែកបាក់ដាច់ដោចសឹករេចរឹលដោយអន្ទើ បណ្តាលឱ្យដាច់បាត់អត្ថបទសិលាចារឹកមួយផ្នែកធំ។ នៅលើពោះគោនន្ទី មានចារឹកតួអក្សរ «ឱំ» ជាតួអក្សរស័ក្តិសិទ្ធិក្នុងព្រហ្មញ្ញសាសនា និងប្រើនៅខាងដើមមន្រ្តគាថាក្នុងភាសាសំស្ក្រឹត។ ចារឹកនៅត្រង់បួរស្មាមុខ និងផ្ទៃខាងមុខ នាំឱ្យយើងអាចយល់បានថា រូបបដិមាឧមាមហេសូរ(ព្រះនាងឧមាគង់លើភ្លៅព្រះឥសូរ)គង់លើនន្ទីនេះ គឺជាតង្វាយរបស់ «ស្តេងសិវាចារ្យ» ដែលជាអាចារ្យព្រះក្រលាអាច្ជំន(ក្រលាបូជា) ថ្វាយចំពោះប្រាសាទបាសែតនេះ។ អត្ថបទនៅផ្នែកខាង

---

[២] អត្ថបទពិស្តារស្តីពីចម្លាក់ឧមាមហេសូរ សូមអាន៖ https://ams.com.kh/khmercivilization/detail/13123។

[៣] សូមថ្លែងអំណរគុណដល់បេក្ខជនបណ្ឌិត ឡេង ស៊ីវ៉ង់ ដែលបានជួយកំណត់រចនាបថរបស់ចម្លាក់នេះ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

ឆ្វេង ចារពីតផ្ទាយរបស់ស្តេងសិវាចារ្យដែលថ្វាយទ្រព្យជារណ្តាប់បូជាទៅព្រះឯលិង្គបុរ (កោះកេរ) រួមមានអង្គរសម្រិត១ថ្លឹង ប្រេង១មាស ជារៀងរាល់ឆ្នាំ។ អត្ថបទខាងឆ្វេងផ្នែកខាងក្រោមនិងបន្តទៅផ្នែកខាងស្តាំ បង្ហាញពីកាលបរិច្ឆេទដែលដាច់បាត់តួលេខខាងដើម និងសាច់រឿងដែលទំនងជាស្តេងសិវាចារ្យជាវដី ព្រមទាំងថ្ងៃជាវនោះរួមមានខាលប្រាក់ ឧបករណ៍គាបទឹកផ្លែឈើ និងកន្ទោរស្តោះផងដែរ។ នៅផ្នែកខាងក្រោយ ជាផ្នែកសំខាន់នៃអត្ថបទចារឹកនេះ ដែលមានចារជាភាសាសំស្ក្រឹតនិងខ្មែរបុរាណ ប៉ុន្តែដោយសារថ្មបាក់បែកនិងសឹករេចរឹល មិនអាចទាញយកព័ត៌មានអ្វីបានច្រើននោះឡើយ ក្រៅតែពីពាក្យខ្មែរប៉ុន្មានពាក្យដែលបង្ហាញស្តេងសិវាចារ្យជាវដីប៉ុណ្ណោះ។

តាមរយៈសិលាចារឹកភាសាខ្មែរ ព្រាហ្មណ៍ឈ្មោះ «សិវាចារ្យ» មានងារជា «ស្តេង» «ស្តេងអញ» និង «កំស្តេងអញ» ដែលមានវត្តមានក្នុងសិលាចារឹកតាំងពីរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ទេវ (៩៤៤ - ៩៦៨ គ.ស.) រហូតដល់រាជ្យព្រះបាទសូរ្យវរ្ម័ទេវទី១។ យោងតាមសិលាចារឹកប្រាសាទភ្នំជីសូរ្យ K.៣៣ បានបង្ហាញថា ស្តេងសិវាចារ្យ ជាអ្នកស្រុកផ្លូវសម៉ (វ្នុំស្រមោ) ដែលអាចស្ថិតនៅក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឬក្នុងស្រុកពួក ខេត្តសៀមរាប។ តាមសិលាចារឹកស្តុកកក់ធំ K.២៣៥ ស្តេងអញសិវាចារ្យ ជាចៅរបស់ស្តេងអញអាត្មសិវៈ និងជាបុរោហិតប្រចាំកម្តែងជគតដំរាជ[៤]ចាប់ពីរាជ្យព្រះបាទជ័យវរ្ម័ទេវទី៥ និងស្លាប់នៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័ទេវទី១។

តាមរយៈសិលាចារឹកថ្មីដែលរកឃើញនៅប្រាសាទបាសែតនេះ នៅផ្ទាំងខាងឆ្វេងនៅសល់កាលបរិច្ឆេទខាងចុងពីរតួគឺ «-៣០គក» ដែលយើងយល់ថាតួលេខដែលបាត់នោះ គួរតែជាលេខ «៩» ពុំអាចជាលេខ «៨» នោះឡើយ។ ដូច្នេះកាលបរិច្ឆេទដែលរំលឹកកាលពីស្តេងសិវាចារ្យជាវដី(?)នោះ គឺមហាសករាជឆ្នាំ៩៣០ ត្រូវនឹងគ្រិស្តសករាជឆ្នាំ១០០៨។ ចំណែកឯកាលបរិច្ឆេទដែលដាច់នៅសល់ត្រឹមលេខ «២» នៅផ្ទាំងខាងស្តាំនោះ គួរតែជាមហាសករាជឆ្នាំ៩៣២ ត្រូវនឹងគ្រិស្តសករាជឆ្នាំ១០១០។ ដូច្នេះ «សិវាចារ្យ» នៅ

[៤] សូមអានបន្ថែមពីពិធីកម្តែងជគតដំរាជ៖ https://ams.com.kh/khmercivilization/detail/8361។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ក្នុងសិលាចារឹកនេះ គឺជា «ស្តេងសិវាចារ្យ» ឬ «ស្តេងអញសិវាចារ្យ» ដែលជាអាចារ្យនាព្រះក្រលាបូជា និងជាបុរោហិតប្រចាំតម្កើងជគតដំរាជ ដែលបម្រើការតាំងពីរាជ្យព្រះបាទជ័យវម៌្មទេវទី៥ រហូតដល់រាជ្យព្រះបាទសូរ្យវម៌្មទេវទី១។

**អត្ថបទចារឹក**

**១- ខាងមុខ**

**ផ្នែកលើគោនន្ទី**

ឱ្ំ[៥]

១- ស្តេងគិវាចាយ៌្យ

២- (ជិះ?)អយ៌លោ(?)

**ផ្នែកចំហៀងខាងឆ្វេង**

១- --្ត

២- កុល

៣- ស្តេញ៊

៤- គិវា

៥- ចាយ៌្យ

៦- នាខ្ញុក

៧- ប្រះក្រ

៨- លាអា

៩- [[ចំណា]]

**២- ខាងឆ្វេង**

**ផ្នែកខាងលើ**

១- -(ថ)្វាយិប្រ(ះ)

២- កោគលិង្គបុរ

៣- គ្វេតតន្ទុល

៤- ថ្ងៃ១ បយ៌្យ

៥- ងមាស៊១ សប

៦- ឆ្នាំ នេះកល្យ

៧- នាស្តេញគិវា

៨- ចាយ៌្យខ្ញុ[[ក៊]]

៩- ប្រ[[ះ]]ក្រលា

១០- អចំណា

**ផ្នែកខាងក្រោម**

១១- -៣០ គ(ក?)

១២- --៦ ស្តេញ

១៣- (គិវាចាយ៌្យ)

**៣- ខាងស្តាំ**

**ផ្នែកខាងលើ**

១- ---(វ)ាបិ-

២- --(បី)លិប្រះ

៣- ---ស្រុកប្រះ

៤- -ិយ៌្យងិ ◦ ថ្វា

៥- យខាលិប្រាក

[៥] ចារនៅលើពោះគោនន្ទី។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៦- ម្វាយ៉លិង(៤?)
៧- ប្វាទ៣ គុតិ--
៨- លិង្គ២ ប្វាទ២ (ប)
៩- ទិគះ១ ជ្យង៤
១០- លង្គៅ២ ជ្យង១
១១- លិង៥ ទ្រវ្យ
១២- នេះស្បង

ផ្នែកខាងក្រោម

១៣- ២គក --------
១៤- ប្រះកម្រ(តេងអញ)-----
១៥- ---(ជ)តតក------

៤- ខាងក្រោយ

ផ្នែកខាងលើ

១- -----------------------------------
២- -----------------------------------

៣- --ភូមិ(ន)-----------------------
៤- -តិថ្មិ-----------------------------
៥- បតុទ្វំ---------------------------
៦- តទាយត្តមិទ-◌្ន◌ុ-------------
៧- រិរ៉ូ-◌្ន◌ា/◌្យ◌ាយេរិ-----------
៨- តេយាន្ដុ-- ---------------------
៩- ---ទ្យ-ត------------------------
១០- --ថ្វាយ----------------------
១១- ជំនួនិស្តេញ(គិរាចាយ៉្យ)---[[អំ]]
១២- វុងិភ្វ(មិ)------------ ◌េ--(ធ)ម្ធំ
១៣- កល្បនា---------------///////

ផ្នែកខាងក្រោម

១៣- ----------◌្ន----◌្ប
១៤- ----ប្រះ--២-------------

## បញ្ជីឯកសារយោង

ជូ ជុន

២០២១. ចម្លាក់ឧមាមហេស្វរ:. https://ams.com.kh/khmercivilization/detail/13123

សុខ កែវ សុវណ្ណារ៉ា

២០២១. ពិធីកម្រតេងជគតតរាជ. https://ams.com.kh/khmercivilization/detail/8361

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

## បញ្ជីរូបភាព



ចម្លាក់តាំងបង្ហាញក្នុងសារមន្ទីរខេត្តបាត់ដំបង (រូបថតៈ ហ៊ិន ឈុនតេង)



ចម្លាក់តាំងបង្ហាញក្នុងសារមន្ទីរខេត្តបាត់ដំបង (រូបថតៈ ហ៊ិន ឈុនតេង)

អត្ថបទដោយៈ ហ៊ិន ឈុនតេង



អត្ថបទចារឹកផ្នែកខាងមុខ (រូបថតៈ ហ៊ិន ឈុនតេង)



អត្ថបទចារឹកផ្នែកខាងឆ្វេង (រូបថតៈ ហ៊ិន ឈុនតេង)

អត្ថបទដោយៈ ហ៊ិន ឈុនតេង



អត្ថបទចារឹកផ្នែកខាងស្តាំ (រូបថតៈ ហ៊ុន ឈុនតេង)



អត្ថបទចារឹកផ្នែកខាងក្រោយ (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង